ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាស្តីពី

## ទំនើបភាវូបនីយកម្មពន្ធដារ ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មាន

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់មេត្តាជ្រាបថា៖ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំធ្វើសិក្ខាសាលាស្តីពីទំនើបភាវូបនីយកម្មពន្ធដារ ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានដល់អ្នកជាប់ពន្ធស្ថិតក្នុងរបបស្វ័យប្រកាស **នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ចាប់ពីម៉ោង ៨.០០ ព្រឹក ដល់ម៉ោង ១២.០០ នាទី រសៀល នៅសណ្ឋាគារសូហ្វីតែលភ្នូកេត្រាភ្នំពេញ។**




សិក្ខាសាលាបានប្រារព្ធឡើងក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពី ឯកឧត្តមអគ្គនាយករង លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខណ្ឌ និងមន្ត្រី នៃអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ជានាយកក្រុមហ៊ុន តំណាងក្រុមហ៊ុន និងសមាគមចំនួន ៩៧៧ នាក់ ដែលតំណាងឲ្យសមាគម និងក្រុមហ៊ុនចំនួន ៧៥៧។

ការរៀបចំឡើងនូវសិក្ខាសាលានេះក្នុងគោលដៅផ្សព្វផ្សាយខ្លឹមសារប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤ ស្តីពីការចុះបញ្ជីពន្ធដារ និង នីតិវិធីពាក់ព័ន្ធការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី ដល់សមាគមនិងក្រុមហ៊ុនទាំងអស់ឲ្យបានយល់ដឹងទូលំទូលាយនូវកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងនីតិវិធីពាក់ព័ន្ធការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី ជាពិសេសភាពងាយស្រួលក្នុងការចុះបញ្ជីថ្មីដោយអនុញ្ញាតឲ្យអ្នកជាប់ពន្ធអាចចុះបញ្ជីតាមរយៈ Online ដែលជាកត្តាលីករមួយយ៉ាងសំខាន់ក្នុងការជួយពង្រឹងនូវការគោរពប្រតិបត្តិច្បាប់ដែលជាកាតព្វកិច្ចខានមិនបានរបស់អ្នកជាប់ពន្ធ ។ តាមរយៈសិក្ខាសាលានេះ អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមនិងជឿជាក់ថាតំណាងសមាគម និងក្រុមហ៊ុនទាំងអស់នឹងទទួលបានចំណេះដឹងថ្មីៗ បន្ថែមទៀត ដើម្បីជាទុនក្នុងការយកទៅអនុវត្តបានត្រឹមត្រូវនូវច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ។

សិក្ខាសាលានឹងផ្តោតលើការស្វែងយល់ពីកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងនីតិវិធីពាក់ព័ន្ធការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី ទំនើបភាវូបនីយកម្មពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកជាប់ពន្ធ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់មេត្តាជ្រាប តាមការគួរ។




